**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

| | |
|---|---|
| សំណុំរឿងលេខ៖ | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក |
| ភាគីដាក់ឯកសារ៖ | លោក **ខៀវ សំផន** |
| ដាក់ជូន៖ | អង្គជំនុំជម្រះតុលាការកំពូល |
| ភាសាដើម៖ | **បារាំង** |
| កាលបរិច្ឆេទឯកសារ៖ | ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 12-Mar-2021, 10:10
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

| | |
|---|---|
| ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ | **សាធារណៈ** |
| ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ | សាធារណៈ/Public |
| ប្រភេទនៃចំណាត់ថ្នាក់៖ | |
| ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖ | |
| ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖ | |
| ហត្ថលេខា៖ | |

---

# សេចក្តីសង្ខេបរបស់ក្រុមមេធាវីការពារក្តី លើកាលវិភាគសម្រាប់សវនាការបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង ០០២/០២

---

| ដាក់ដោយ៖ | ដាក់ជូន៖ |
|---|---|
| **មេធាវីការពារក្តីលោក ខៀវ សំផន** | **អង្គជំនុំជម្រះតុលាការកំពូល៖** |
| មេធាវី គង់ សំអុន | ចៅក្រម គង់ ស្រីម |
| មេធាវី Anta GUISSÉ | ចៅក្រម Chandra Nihal JAYASINGHE |
| | ចៅក្រម សោម សិរីវឌ្ឍ |
| | ចៅក្រម Florence Ndepele MWACHANDE-MUMBA |

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

លោក តាន់ ឆាយរ័ត្ន

កញ្ញា Mathilde CHIFFERT

ក្រុម ម៉ុង មុន្នីចរិយា

ចៅក្រម Maureen HARDING CLARK

ចៅក្រម យ៉ា ណារិន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោកស្រី Brenda J. HOLLIS

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

១. នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ អង្គជំនុំជម្រះតុលាការកំពូល ("តុលាការកំពូល") បានផ្ញើជូនភាគី នូវកាលវិភាគបណ្តោះអាសន្ន សម្រាប់សវនាការបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង ០០២/០២ ដែលត្រូវបានរៀបចំទៅតាមប្រធានបទ និងបានស្នើឲ្យភាគីដាក់សេចក្តីសង្កេតជាយថាហេតុ។ តុលាការកំពូលក៏បានជូនដំណឹងដល់ភាគីថា កាលវិភាគស្ថាពរនឹងចេញក្នុងពេលឆាប់ៗ ដោយមានកំណត់ជាសំណួរជាក់លាក់ ដែលភាគីត្រូវបានរំពឹងទុកថានឹងផ្តោតលើបញ្ហាទាំងនោះ នៅក្នុងសវនាការ[1]។

២. តាមរយៈសារណានេះ ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ("មេធាវីការពារក្តី") ដាក់សេចក្តីសង្កេតមួយចំនួន លើកាលវិភាគបណ្តោះអាសន្ន ជាលក្ខណៈទូទៅ (ផ្នែកទី ១) និងជាក់លាក់ តាមប្រធានបទ (ផ្នែកទី ២) ព្រមទាំងលើកជាសំណើផ្សេងៗ។ មេធាវីការពារក្តីសូមបញ្ជាក់ថា សេចក្តីសង្កេតទាំងនេះពុំមានលក្ខណៈគ្រប់ជ្រុងជ្រោយទេ ដោយសារតែពុំមានសំណួរជាក់លាក់ពីតុលាការកំពូលទៅលើបញ្ហាដែលខ្លួននឹងត្រូវផ្តោតលើ នៅក្នុងសវនាការ។

## ១. សេចក្តីសង្កេតជាទូទៅ

៣. ក្នុងកាលវិភាគបណ្តោះអាសន្ន តុលាការកំពូលបានរៀបចំសវនាការ ជាបីវគ្គ៖ វគ្គបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន (ចែកចេញជាច្រើនប្រធានបទ) វគ្គបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា និងវគ្គបិទសវនាការ។ តុលាការកំពូលបានបែងចែកពេលវេលាឲ្យភាគីធ្វើសារណាផ្ទាល់មាត់សម្រាប់ប្រធានបទនីមួយៗ។

៤. ការបែងចែកពេលវេលានេះបង្ហាញឲ្យឃើញអតុល្យភាពយ៉ាងខ្លាំងរវាងភាគី ដោយធ្វើឲ្យប៉ះពាល់ដល់ប្រយោជន៍របស់មេធាវីការពារក្តី។ ជាក់ស្តែង សម្រាប់បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី យើងទទួលបាន ៣ ម៉ោង និង ៥៥ នាទី ដើម្បីធ្វើសារណា ចំណែកឯសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") ទទួលបានពេលវេលារួមគ្នា ៥ ម៉ោង

[1] ការអញ្ជើញដាក់សេចក្តីសង្កេតលើកាលវិភាគសម្រាប់សវនាការបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ ឯកសារ **F60**, ឧបសម្ព័ន្ធ - កាលវិភាគសវនាការ ឯកសារ **F60.1**។

ដើម្បីឆ្លើយតប។ ចំណុចនេះមិនសមាមាត្រគ្នាសោះ និងរុញមេធាវីការពារក្តីឲ្យធ្លាក់ទៅក្នុងស្ថានភាពចាញ់ប្រៀបច្បាស់ក្រឡែត ធៀបនឹងគូបដិបក្ខរបស់ខ្លួន។ ដើម្បីកំណត់ទិសដៅនៃសេចក្តីសង្កេតរបស់ខ្លួនឲ្យបានច្បាស់ លើការបែងចែកពេលវេលាដែលបានស្នើឡើង មេធាវីការពារក្តីយល់ឃើញថាចាំបាច់ត្រូវរម្លឹកអំពីគោលបំណងនៃសវនាការបណ្តឹងសាទុក្ខ (១.១) ភាពខុសគ្នានៃឋានៈរបស់ភាគី (១.២) និងការកម្រិតតឹងរ៉ឹងនៃការចូលរួមរបស់សហមេធាវីនាំមុខ (១.៣)។

## ១.១. គោលបំណងនៃសវនាការបណ្តឹងសាទុក្ខ

៥. ក្រោយពីដាក់សេចក្តីសន្និដ្ឋានលើបណ្តឹងសាទុក្ខ វិធានផ្ទៃក្នុងកំណត់អំពីការរៀបចំសវនាការ ដោយចែងជាអាទិ៍ថា៖

> "ម្ចាស់បណ្តឹងសាទុក្ខអាចធ្វើសារណាបញ្ជាក់អំពីមូលដ្ឋាននៃបណ្តឹងសាទុក្ខ ហើយភាគីដទៃទៀតក៏អាចធ្វើសារណាឆ្លើយតបបានដែរ។ ចៅក្រមទាំងអស់អាចសួរសំណួរទាំងឡាយដែលខ្លួនយល់ថាអាចឈានទៅដល់ការធ្វើសេចក្តីវិនិច្ឆ័យ ចំពោះបណ្តឹងសាទុក្ខ។
>
> គ្រប់ករណីទាំងអស់ ជនជាប់ចោទត្រូវនិយាយក្រោយគេបំផុត។ មេធាវីរបស់ជនជាប់ចោទត្រូវបានអនុញ្ញាតឲ្យធ្វើសេចក្តីសន្និដ្ឋានតបដោយសង្ខេប"[2]។

៦. ក្នុងករណីនេះ ដូចក្នុងសំណុំរឿង ០០២/០១[3] ដែរ តុលាការកំពូលបានសម្រេចថា ការឆ្លើយតបណាមួយទៅនឹងសារណាតប នឹងត្រូវស្តាប់ ក្នុងសវនាការ[4]។ ក្នុងសំណុំរឿង ០០២/០១ តុលាការកំពូលបានប្រកាសថា៖

---

[2] វិធាន ១០៩(៤) និងវិធាន ១០៩(៦)។

[3] សេចក្តីសម្រេចលើសំណើសុំពន្យាររយៈពេល និងបន្ថែមចំនួនទំព័រ សម្រាប់សារណាបណ្តឹងសាទុក្ខ និងសារណាតប ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ឯកសារ F9 កថាខណ្ឌ ២២ និងកថាខណ្ឌ ២៣។

[4] សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រ សម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ ឯកសារ F49 កថាខណ្ឌ ៣៦។

"គោលបំណងនៃសវនាការបណ្ដឹងសាទុក្ខនេះ គឺពុំមែនដើម្បីហាត់សមទឡ្ហីករណ៍ដែលបានលើកឡើងដោយភាគីកន្លងមក នៅក្នុងសារណាជាលាយលក្ខណ៍អក្សរនោះឡើយ ប៉ុន្តែ ជាចម្បង គឺដើម្បីផ្ដល់ឱកាសឲ្យភាគីក្នុងការឆ្លើយតបទៅនឹងសារណាតបរបស់ភាគីដទៃទៀត និងឆ្លើយនូវសំណួររបស់អង្គជំនុំជម្រះតុលាការកំពូល"[5]។

៧. នៅពេលនោះ តុលាការកំពូលបានបន្ថែមទៀតថា "អាស្រ័យហេតុនេះ ពុំមានហេតុផលអ្វីដែលត្រូវផ្ដល់ឲ្យសហព្រះរាជអាជ្ញា នូវពេលវេលាដូចគ្នាទៅនឹង នួន ជា និង ខៀវ សំផន ក្នុងការធ្វើសារណារបស់ខ្លួនឡើយ"[6]។

៨. ដូច្នេះ សវនាការបណ្ដឹងសាទុក្ខត្រូវអនុញ្ញាតឲ្យម្ចាស់បណ្ដឹងសាទុក្ខបង្ហាញដោយសង្ខេបនូវមូលដ្ឋានបណ្ដឹងសាទុក្ខរបស់ខ្លួន និងជាពិសេស ឆ្លើយតបទៅនឹងភាគីដទៃទៀត បន្ថែមពីលើការឆ្លើយទៅនឹងសំណួររបស់តុលាការកំពូល។ អាស្រ័យហេតុនេះ វាជាការសមហេតុផលដែលម្ចាស់បណ្ដឹងសាទុក្ខត្រូវទទួលបានពេលវេលាច្រើនជាងភាគីដទៃទៀត។

## ១.២. <u>ភាពខុសគ្នានៃឋានៈរបស់ភាគី</u>

៩. ក្នុងរឿងក្ដីនេះ ដូចបានរម្លឹករួចមកហើយ[7] តុលាការកំពូលបានទទួលបណ្ដឹងសាទុក្ខចំនួនពីរ ដែលបានធ្វើឡើងដោយ ខៀវ សំផន និងសហព្រះរាជអាជ្ញា។ លោក ខៀវ សំផន បានប្ដឹងសាទុក្ខប្រឆាំងនឹងការផ្ដន្ទាទោសពីបទឧក្រិដ្ឋជាច្រើនដែលបានចោទប្រកាន់ និងការផ្ដន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត។ សហព្រះរាជអាជ្ញាបានប្ដឹងសាទុក្ខប្រឆាំងនឹងការសម្រេចលើកលែងលោក ខៀវ សំផន ឲ្យរួចផុតពីការចោទប្រកាន់ពីបទឧក្រិដ្ឋតែមួយគត់។

---

[5] ដីកាកំណត់កាលវិភាគស្ដាពរ សម្រាប់សវនាការបណ្ដឹងសាទុក្ខ និងការជូនដំណឹងភាគីអំពីបញ្ហានានាដែលត្រូវលើកឡើង ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ ឯកសារ **F30/4** ទំព័រ ៥។

[6] ដូចខាងលើ។

[7] ការអញ្ជើញដាក់សេចក្ដីសង្កេតលើកាលវិភាគសម្រាប់សវនាការបណ្ដឹងសាទុក្ខ ក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ ឯកសារ **F60** ទំព័រ ៥។

១០. សហមេធាវីនាំមុខមិនបានប្រើលទ្ធភាពដែលបានផ្តល់ជូន ដើម្បីធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ពាក់ព័ន្ធនឹងសេចក្តីសម្រេចលើសំណង និងបញ្ហាពិរុទ្ធភាព នោះទេ ខណៈដែលបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាបានបើកផ្លូវឲ្យធ្វើទៅហើយ[8]។

១១. ដូច្នេះ នៅក្នុងក្របខ័ណ្ឌនៃបណ្តឹងសាទុក្ខរបស់ខ្លួន ក្នុងសវនាការ លោក ខៀវ សំផន មានឋានៈជាម្ចាស់បណ្តឹងសាទុក្ខ ហើយត្រូវឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ ដែលមានឋានៈជាចុងបណ្តឹងសាទុក្ខ។ នេះជាឱកាសលើកដំបូង និងតែម្តងគត់ ដែលបានផ្តល់ជូនមេធាវីការពារក្តី ដើម្បីធ្វើការឆ្លើយតប។

១២. នៅក្នុងក្របខ័ណ្ឌនៃបណ្តឹងសាទុក្ខរបស់ខ្លួន សហព្រះរាជអាជ្ញាមានឋានៈជាម្ចាស់បណ្តឹងសាទុក្ខ ហើយត្រូវឆ្លើយតបទៅនឹងចម្លើយតបរបស់មេធាវីការពារក្តី ដែលមានឋានៈជាចុងបណ្តឹងសាទុក្ខ។ សហមេធាវីនាំមុខពុំមានឋានៈជាម្ចាស់បណ្តឹងសាទុក្ខ ឬជាចុងបណ្តឹងសាទុក្ខឡើយ[9]។ សហមេធាវីនាំមុខជាភាគីនៃកិច្ចដំណើរការនីតិវិធី ដើម្បីគាំទ្រដល់សហព្រះរាជអាជ្ញា ដោយទទួលបានសិទ្ធិចូលរួមមានកម្រិត ហើយសិទ្ធិចូលរួមនេះកាន់តែមានកម្រិតទៀត ក្នុងដំណាក់កាលបណ្តឹងសាទុក្ខ។

## ១.៣. ការកម្រិតតឹងរ៉ឹងនៃការចូលរួមរបស់សហមេធាវីនាំមុខ

### ១.៣.១. មូលដ្ឋានសម្រួបនៃការកម្រិតការចូលរួមរបស់សហមេធាវីនាំមុខ

១៣. នៅ អ.វ.ត.ក ក្នុងការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌ រួមជាមួយបណ្តឹងរដ្ឋប្បវេណីដែលអនុញ្ញាតឲ្យជនរងគ្រោះចូលរួមជាភាគីនៃកិច្ចដំណើរការនីតិវិធី ដើម្បីទទួលបានសំណងពីព្យសនកម្ម ក្នុងករណី

---

[8] វិធាន ១០៥(១) នៃវិធានផ្ទៃក្នុង៖ "បណ្តឹងសាទុក្ខប្រឆាំងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងអាចធ្វើឡើងដោយ៖ ក- សហព្រះរាជអាជ្ញា ខ- ជនជាប់ចោទ គ- ដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់ពាក្យបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចស្តីពីសំណង។ នៅពេលដែលសហព្រះរាជអាជ្ញាបានធ្វើបណ្តឹងសាទុក្ខរួចហើយ ដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់ពាក្យបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម។ ដើមបណ្តឹងរដ្ឋប្បវេណីមិនអនុញ្ញាតឲ្យធ្វើបណ្តឹងសាទុក្ខលើសេចក្តីសម្រេចផ្តន្ទាទោសបានឡើយ"។

[9] សូមមើល ជាអាទិ៍៖ សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ **F10/2** ("សេចក្តីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ **F10/2**") កថាខណ្ឌ ២៣ និងកំណត់សម្គាល់ជើងទំព័រលេខ ៦០។

មានការផ្តន្ទាទោស មេធាវីការពារក្តី ជាតំណាងឲ្យជនជាប់ចោទ តទល់នឹងភាគីពីរផ្សេងទៀតដែលតំណាងឲ្យផលប្រយោជន៍ផ្សេងគ្នា គឺផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ដោយឡែករបស់ដើមបណ្តឹងរដ្ឋប្បវេណី។

១៤. ជាបឋម មេធាវីការពារក្តីតទល់នឹងសហព្រះរាជអាជ្ញា ដែលជាអ្នកផ្តើម និងអនុវត្តបណ្តឹងអាជ្ញា តាងនាមឲ្យផលប្រយោជន៍ទូទៅ (រួមបញ្ចូលជាចាំបាច់នូវផលប្រយោជន៍រួមរបស់ជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់)។ ព្រះរាជអាជ្ញាជាអ្នកទាមទារឲ្យអនុវត្តច្បាប់ នៅចំពោះមុខតុលាការ ក្នុងក្របខ័ណ្ឌនៃបណ្តឹងព្រហ្មទណ្ឌ[10]។

១៥. បន្ទាប់មក មេធាវីការពារក្តីតទល់នឹងសហមេធាវីនាំមុខ ដែលមិនអាចផ្តើមការចោទប្រកាន់បានទេ នៅ អ.វ.ត.ក ប៉ុន្តែ ចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ដើម្បីគាំទ្រដល់សហព្រះរាជអាជ្ញា សំដៅទទួលបានសំណងពីព្យសនកម្មដែលពួកគេបានទទួលរង ក្នុងករណីជនជាប់ចោទត្រូវបានទទួលស្គាល់ថាមានពិរុទ្ធភាព។ សហមេធាវីនាំមុខធ្វើសកម្មភាព ក្នុងក្របខ័ណ្ឌនៃបណ្តឹងរដ្ឋប្បវេណី[11]។

១៦. ប្រការនេះនាំឲ្យ "បណ្តឹងរដ្ឋប្បវេណី គឺជាបណ្តឹងរណប ពោលគឺពុំមែនបណ្តឹងមួយផ្សេងពីបណ្តឹងរបស់សហព្រះរាជអាជ្ញានោះទេ"[12]។ ដើម្បីធានាតុល្យភាពរវាងសិទ្ធិរបស់ភាគី "វាជាការចាំបាច់ដែលថា ការបកស្រាយក្នុងន័យទូលាយលើបុព្វសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវឲ្យរំលោភលើសិទ្ធិមូលដ្ឋានរបស់ជនជាប់ចោទ រារាំងដល់ការបំពេញមុខងាររបស់ស្ថាប័នអយ្យការ ឬប៉ះពាល់ដល់ការប្រព្រឹត្តិទៅនៃកិច្ចដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធភាពនោះទេ"[13]។ ដូច្នេះ៖

---

[10] សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឲ្យចេញសេចក្តីសម្រេចអំពីសិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលបានកោះហៅឲ្យផ្តល់សក្ខីកម្ម ទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៩ សំណុំរឿង ០០១ ឯកសារ **E72/3** ("សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៩ ឯកសារ **E72/3**") កថាខណ្ឌ ១៨-២២។ សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលារបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងរដ្ឋប្បវេណី សម្រាប់សួរដេញដោលសាក្សី SCW-5 ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ **F26/2/2** កថាខណ្ឌ ៦-៧។

[11] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៩ ឯកសារ **E72/3** កថាខណ្ឌ ១១-១៣ កថាខណ្ឌ ២៥។

[12] សេចក្តីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ **F10/2** កថាខណ្ឌ ១២។

[13] ដូចខាងលើ។

"សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ រួមមានទាំងសិទ្ធិប្រឈមមុខទៅនឹងអាជ្ញាធរចោទប្រកាន់តែមួយប៉ុណ្ណោះ។ ដូច្នេះហើយ នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិគាំទ្រ ឬជួយដល់អយ្យការ ដូចដែលកំពុងអនុវត្តនេះ តួនាទីរបស់ពួកគេនៅក្នុងការជំនុំជម្រះក្តីនេះ មិនត្រូវប្រែក្លាយទៅជាព្រះរាជអាជ្ញាបន្ថែមទៀតបានទេ"[14]។

១៧. ពេលបដិសេធសំណើរបស់សហមេធាវីនាំមុខសុំបញ្ចេញយោបល់ពាក់ព័ន្ធនឹងទោស ក្នុងសំណុំរឿង ០០១ (ពីព្រោះជាសមត្ថកិច្ចផ្តាច់មុខរបស់អយ្យការដែលធ្វើឡើងដើម្បីផលប្រយោជន៍សាធារណៈ)[15] អង្គជំនុំជម្រះសាលាដំបូងបានរម្លឹកគោលការណ៍ពីរ៖

"ទីមួយ ផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីមានន័យថា ត្រូវតែស្វែងរកសំណង។ ទោះជាយ៉ាងនេះក្តី តម្រូវការបឋមសម្រាប់សំណង គឺការរកឃើញពិរុទ្ធភាព។ ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីក៏មានផលប្រយោជន៍ ក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងកំណត់បានធាតុផ្សំនៃបទល្មើស នៅពេលដែលមានភស្តុតាងបញ្ជាក់ ដែលបានបង្កើតបានជាមូលដ្ឋានសម្រាប់បណ្តឹងរដ្ឋប្បវេណីទាមទារសំណងរបស់ខ្លួន។ ចំពោះហេតុផលនេះ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានផ្តល់សិទ្ធិឱ្យគាំទ្រដល់អយ្យការ ក្នុងការកំណត់បាននូវធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌទៅលើជនជាប់ចោទ ដែលមានឥទ្ធិពលទៅលើដើមបណ្តឹងរដ្ឋប្បវេណី និងបង្កើតជាមូលដ្ឋានសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីទាមទារសំណង។

ទីពីរ គោលបំណងទាំងមូលនៃនីតិវិធីព្រហ្មទណ្ឌកម្ពុជាគឺផ្តល់ការពិត។ ភាគីទាំងអស់អាចជួយឱ្យសម្រេចគោលបំណងនេះ។ ដោយមានប្រយោជន៍ជាមូលដ្ឋាន ដើម្បីទទួលបានសំណងចំពោះដើមបណ្តឹងរដ្ឋប្បវេណី ការផ្តល់ការពិត គឺកំណត់ចំពោះអង្គហេតុ ឬកត្តានានាដែល

---

[14] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៩ ឯកសារ E72/3 កថាខណ្ឌ ២៦។

[15] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៩ ឯកសារ E72/3 កថាខណ្ឌ ៤២។

ទាក់ទងទៅនឹងការកំណត់ពិរុទ្ធភាព ឬគ្មានពិរុទ្ធភាពនៃជនជាប់ចោទ”[16] (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

១៨. ដូច្នេះ ខណៈដែលសហព្រះរាជអាជ្ញាទទួលបន្ទុកលើបញ្ហាពាក់ព័ន្ធនឹងការអនុវត្តច្បាប់ ដើម្បីផលប្រយោជន៍ទូទៅ (រួមបញ្ចូលទាំងផលប្រយោជន៍រួមរបស់ជនរងគ្រោះ) សហមេធាវីនាំមុខគាំទ្រដល់សហព្រះរាជអាជ្ញា ទៅលើបញ្ហាពាក់ព័ន្ធនឹងភ័ស្តុតាងស្តីពីអត្ថិភាពនៃអំពើឧក្រិដ្ឋដែលបានចោទប្រកាន់ ដើម្បីផលប្រយោជន៍ដោយឡែករបស់ខ្លួន និងជាក់លាក់បំផុត គឺដើម្បីទទួលបានសំណង។

១៩. សហមេធាវីនាំមុខមិនអាចចេញហួសពីក្របខ័ណ្ឌនេះ ដោយមិនទន្ទ្រានយកបុព្វសិទ្ធិរបស់សហព្រះរាជអាជ្ញានោះឡើយ និងមិនអាចដើរតួជាព្រះរាជអាជ្ញាបន្ថែមទៀតឡើយ ហើយក៏មិនអាចបំបែកសមភាពនៃមធ្យោបាយតទល់ក្តីបានដែរ។ សូមរម្លឹកថា នៅ អ.វ.ត.ក នីតិវិធីមានលក្ខណៈស្មុគស្មាញជាង ហើយជនរងគ្រោះមានចំនួនច្រើនជាង នៅក្នុងច្បាប់ជាតិ[17]។ នីតិវិធីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមមានលក្ខណៈបច្ចេកទេសជាង ដោយតុលាការកំពូលដើរតួជាសាលាឧទ្ធរណ៍ផង និងជាតុលាការសម្រេចសេចក្តីចុងក្រោយផង[18]។ នេះមិនមែនជាការជំនុំជម្រះក្តីថ្មីនោះទេ ហើយវិសាលភាពនៃការចូលរួមរបស់សហមេធាវីនាំមុខកាន់តែមានកម្រិតទៅទៀត[19] ជាពិសេសនៅពេលសហមេធាវីនាំមុខមិនមែនជាម្ចាស់បណ្តឹងសាទុក្ខ។

---

[16] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៩ ឯកសារ **E72/3** កថាខណ្ឌ ៣៣ និង កថាខណ្ឌ ៣៤។

[17] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៩ ឯកសារ **E72/3** កថាខណ្ឌ ១២។

[18] សាលដីកាសំណុំរឿង ០០១ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ **F28** កថាខណ្ឌ ១២-១៣។

[19] ឧទាហរណ៍ ខណៈដែលវិធានផ្ទៃក្នុងអនុញ្ញាតឲ្យ “ភាគី” ធ្វើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចណាមួយរបស់អង្គជំនុំជម្រះសាលាដំបូង (វិធាន ១០៥.២) វិធានផ្ទៃក្នុងកម្រិតលទ្ធភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ត្រឹមសេចក្តីសម្រេចស្តីពីសំណង និងបញ្ហាពិរុទ្ធភាពប៉ុណ្ណោះ ក្នុងករណីសហព្រះរាជអាជ្ញាបានធ្វើបណ្តឹងសាទុក្ខរួចហើយ។ ម្យ៉ាងវិញទៀត វិធានផ្ទៃក្នុងមិនអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចស្តីពីទោសបានឡើយ (វិធាន ១០៥.១)។

**១.៣.២. វិសាលភាពនៃការកម្រិតការចូលរួមរបស់សហមេធាវីនាំមុខ ក្នុងនីតិវិធីបណ្តឹងសាទុក្ខ ប្រឆាំងនឹងសាលក្រម ដែលខ្លួនមិនមែនជាម្ចាស់បណ្តឹងសាទុក្ខ**

២០. តាំងពីសំណុំរឿង 00២/0១ ដែលសហមេធាវីនាំមុខក៏មិនមែនជាម្ចាស់បណ្តឹងសាទុក្ខ តុលាការកំពូលបានរម្លឹកថា សហមេធាវីនាំមុខចូលរួមក្នុងឋានៈជាភាគីនៃកិច្ចដំណើរការនីតិវិធី "ដោយមានការបញ្ជាក់ដែលសហមេធាវីនាំមុខបានទទួលស្គាល់យ៉ាងច្បាស់រួចហើយថា អាស្រ័យទៅតាមមុខងាររៀងៗគ្នា ភាគីនីមួយៗមានសិទ្ធិខុសៗគ្នា ក្នុងការចូលរួមនៅក្នុងកិច្ចដំណើរការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌ"[20]។ ដោយរម្លឹកអំពី "តម្រូវការក្នុងការការពារសមភាពនៃមធ្យោបាយតទល់ក្តីគ្នា និងក្តីបារម្ភនានាទាក់ទងនឹងការរៀបចំកិច្ចដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធភាពនោះ" តុលាការកំពូលបានរឹតត្បិតការអនុវត្តសិទ្ធិរបស់សហមេធាវីនាំមុខ ក្នុងការឆ្លើយតបនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី៖

> "ទីមួយ ទឡ្ហីករណ៍ដែលបានលើកឡើងនៅក្នុងសារណាតបដែលបានស្នើឡើង ត្រូវតែទាក់ទិនទៅនឹងមូលហេតុនានា ដែលប៉ះពាល់ដោយផ្ទាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី។ ទីពីរ សហមេធាវីនាំមុខត្រូវតែព្យាយាមបញ្ចៀសនូវភាពច្រំដែល និងភាពជាន់គ្នាទៅលើបញ្ហានានា ដែលមានរួចហើយ នៅក្នុងសារណាតប ដែលសហព្រះរាជអាជ្ញាបានគ្រោងរៀបចំឡើងប្រឆាំងទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី"[21] (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

២១. លក្ខខណ្ឌរឹតត្បិតទាំងពីរនេះមានភាពច្បាស់លាស់ណាស់ ហើយស្របនឹងមុខងារ និងការទទួលខុសត្រូវជាក់លាក់នៃគូបដិបក្ខរបស់មេធាវីការពារក្តី៖ សហមេធាវីនាំមុខត្រូវឆ្លើយតបតែទៅលើបញ្ហាដែលពាក់ព័ន្ធដោយផ្ទាល់នឹងផលប្រយោជន៍ជាក់លាក់ ពោលគឺបញ្ហាទាក់ទងនឹងភ័ស្តុតាងដែលដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ជូន ទាក់ទិននឹងអត្ថិភាពនៃអំពើឧក្រិដ្ឋដែលបានចោទប្រកាន់ ដើម្បីទទួលបានសំណង។ សហមេធាវីនាំមុខមិនត្រូវធ្វើអន្តរាគមន៍លើបញ្ហាដែលសហព្រះរាជអាជ្ញាបានលើកឡើងរួចមកហើយ ក្នុងតួនាទីអនុវត្តច្បាប់ ដើម្បីផលប្រយោជន៍ទូទៅ ដែលក្តោបរួចទៅហើយលើ

[20] សេចក្តីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ F10/2 កថាខណ្ឌ ១៥។

[21] សេចក្តីសម្រេចរបស់តុលាការកំពូល ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ F10/2 កថាខណ្ឌ ១៧។

ផលប្រយោជន៍រួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងពាក់ព័ន្ធដោយប្រយោលនឹងផលប្រយោជន៍ដោយឡែករបស់ពួកគេ។

២២. រហូតមកទល់នឹងពេលថ្មីៗនេះ សហមេធាវីនាំមុខបានចេញហួសក្របខ័ណ្ឌនេះដែលត្រូវបានកម្រិតយ៉ាងតឹងរ៉ឹងតែមួយលើកគត់ ពេលសហមេធាវីនាំមុខបានឆ្លើយជំទាស់ទៅនឹងសំណើសុំភ័ស្តុតាងបន្ថែមរបស់ នួន ជា ក្នុងបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១។ តុលាការកំពូលបានអះអាងថា ការលើកឡើងអំពីការចង់បានតុល្យភាពរបស់ភាគី នៅក្នុងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានសាលក្រម ក្នុងពេលវេលាសមស្រប មានលក្ខណៈ "ទូទៅ" ពេក ពុំអាចបំពេញតាមគោលការណ៍ និងលក្ខខណ្ឌវិតត្បិតដែលមាននៅក្នុងយុត្តិសាស្ត្ររបស់ខ្លួន។ អាស្រ័យហេតុនេះ តុលាការកំពូលមិនពិចារណាលើសារណារបស់សហមេធាវីនាំមុខទេ[22]។

២៣. ក្រៅពីការប្រាសចាកនេះ សហមេធាវីនាំមុខមិនបានចេញហួសក្របខ័ណ្ឌនេះទេ និងបានគោរពតាមលក្ខខណ្ឌវិតត្បិតទាំងពីររបស់តុលាការកំពូល ដែលដើមបណ្តឹងរដ្ឋប្បវេណីតែងតែលើកយកមករម្លឹកជានិច្ច។

២៤. នៅក្នុងសំណុំរឿង ០០២/០១ សហមេធាវីនាំមុខបានដាក់ចម្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ក្រុមមេធាវីការពារក្តី ដោយផ្តោតលើមូលដ្ឋានបណ្តឹងសាទុក្ខ ពាក់ព័ន្ធនឹងបញ្ហាដែលប៉ះពាល់ដល់ភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី[23]។ សហមេធាវីនាំមុខបានធ្វើអន្តរាគមន៍ ក្នុងសវនាការបណ្តឹងសាទុក្ខ តែលើបញ្ហាទាំងនេះប៉ុណ្ណោះ[24]។

---

[22] សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **F36** កថាខណ្ឌ ៨១។

[23] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទៅនឹងបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **F17/2** (សារណានេះត្រូវបានបកប្រែជាភាសាបារាំង ប៉ុន្តែ មេធាវីការពារក្តីមិនដឹងថា ហេតុអ្វីបានជាសំណៅបកប្រែមិនត្រូវបានដាក់ចូលក្នុងសំណុំរឿង ឬជូនដំណឹង)។ សូមមើល ជាអាទិ៍ កថាខណ្ឌ ៣ អំពីការរម្លឹកលក្ខខណ្ឌវិតត្បិតពីររបស់តុលាការកំពូល និងកថាខណ្ឌ ៤៖ "ដោយសារថាចម្លើយតបរបស់សហព្រះរាជអាជ្ញាដោះស្រាយបានគ្រប់ជ្រុងជ្រោយទៅលើមូលដ្ឋានមួយចំនួននៃបណ្តឹងសាទុក្ខ នៅក្នុងបណ្តឹងសាទុក្ខទាំងពីររបស់ជនជាប់ចោទនោះ ទើបសហមេធាវីនាំមុខផ្តោតលើតែមូលដ្ឋាននៃបណ្តឹងសាទុក្ខដែលពាក់ព័ន្ធនឹងបញ្ហាស្នូលផ្នែកច្បាប់ដែលប៉ះពាល់ដល់ភ័ស្តុតាងដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ"។

[24] ឧបសម្ព័ន្ធ ក - កាលវិភាគស្តាពរសម្រាប់សវនាការ [សំណុំរឿង ០០២/០១] ឯកសារ **F30/17.1**, ប្រតិចារឹកសវនាការ ថ្ងៃទី

២៥. នៅក្នុងសំណុំរឿង ០០២/០២ ពេលដាក់សេចក្តីសង្កេតលើចម្លើយតបរបស់មេធាវីការពារក្តី ទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា សហមេធាវីនាំមុខបានបញ្ជាក់ថា សារណា (១) លើកឡើងបញ្ហានានា "ដែលប៉ះពាល់ដោយផ្ទាល់ទៅលើសិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី" ជាពិសេស ទាក់ទិននឹងភាពអាចជឿជាក់បាន ភាពអាចទុកចិត្តបាន និងភាពពាក់ព័ន្ធនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានមេធាវីការពារក្តីជំទាស់តវ៉ា និង (២) មិនគ្រប ដណ្តប់ទៅលើបញ្ហានានាដែលសហព្រះរាជអាជ្ញាបានលើកឡើងរួចមកហើយ[25]។ សហមេធាវីនាំមុខមិនបានធ្វើសេចក្តីសង្កេតណាមួយលើទឡ្ហីករណ៍របស់មេធាវីការពារក្តី ពាក់ព័ន្ធនឹងច្បាប់ជាធរមានឡើយ។

២៦. ដូចគ្នាផងដែរ ពេលស្នើសុំបន្ថែមពេលវេលា និងចំនួនទំព័រ ដើម្បីឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី សហមេធាវីនាំមុខបានប្រកាសអំពីចេតនារបស់ខ្លួន ក្នុងការឆ្លើយតប "ដោយសារសារណានោះប៉ះពាល់ដោយផ្ទាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី"[26] និងបានអះអាងថា ភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានសារៈសំខាន់ ក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន[27]។

២៧. ក្នុងបរិបទនេះ តុលាការកំពូលបានផ្តល់ជូនសហមេធាវីនាំមុខស្មើរតែទាំងស្រុងនូវវិធានការដែលបានស្នើសុំ ដោយរម្លឹកអំពីយុត្តិសាស្ត្រមុនៗ និងកត់សម្គាល់អំពីចេតនារបស់សហមេធាវីនាំមុខ ក្នុងការដកស្រង់[28]។

---

១៦ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ **F1/5.1** ទំព័រ ៤៨-៥៧ ចន្លោះម៉ោង 14.00.05 ដល់ម៉ោង 14.27.49។ ក្រៅពីនេះទៀត សហមេធាវីនាំមុខមិនបានដាក់សារណាស្តីពីការកែប្រែបទចោទដែលតុលាការកំពូលបានគ្រោងឡើងនោះទេ (ដីកាកំណត់កាលបរិច្ឆេទសវនាការបណ្តឹងសាទុក្ខ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ឯកសារ **F30**) ដែលពាក់ព័ន្ធដោយប្រយោលនឹងផលប្រយោជន៍ដោយឡែករបស់ដើមបណ្តឹងរដ្ឋប្បវេណី។

[25] សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទិននឹងចម្លើយតបរបស់ ខៀវ សំផន ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៩ ឯកសារ **F50/1/1** កថាខណ្ឌ ៨-៩។

[26] សំណើនានាពាក់ព័ន្ធនឹងចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ ឯកសារ **F52** កថាខណ្ឌ ២ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[27] ដូចខាងលើ កថាខណ្ឌ ១០។

[28] សេចក្តីសម្រេចលើសំណើពាក់ព័ន្ធនឹងសារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទៅនឹងបណ្តឹង

២៨. ផ្ទុយទៅវិញ តាមរយៈការសង្កេតរបស់មេធាវីការពារក្តី នៅក្នុងដំណាក់កាលនេះ ច្បាស់ណាស់ថា សហមេធាវីនាំមុខបានចេញហួសពីចេតនាដំបូងរបស់ខ្លួន និងលក្ខខណ្ឌរឹតត្បិតដែលបានកំណត់។ សូមជម្រាបថា សារណាតបរបស់សហមេធាវីនាំមុខមិនទាន់ត្រូវបានបកប្រែជាភាសាបារាំងនៅឡើយទេ (គឺនឹងត្រូវបកប្រែចប់ ក្រោយកាលកំណត់ដាក់សេចក្តីសង្កេតនេះ)[29]។ សហមេធាវីនាំមុខបានឆ្លើយតបលើបញ្ហាជាច្រើន ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់សហព្រះរាជអាជ្ញាដែលបានឆ្លើយតបដោយខ្លួនឯងរួចមកហើយ។ សហមេធាវីនាំមុខបានដើរតួដូចជាសហព្រះរាជអាជ្ញាបន្ថែម និងធ្វើឱ្យគេឯងគ្រប់គ្នាទទួលយកនិន្នាការ(?)កម្ម។

២៩. ការចេញហួសទាំងនេះផ្ទុះបញ្ជាំងឱ្យឃើញ នៅក្នុងកាលវិភាគបណ្តោះអាសន្ន សម្រាប់សវនាការបណ្តឹងសាទុក្ខ ដែលមេធាវីការពារក្តីនឹងធ្វើសេចក្តីសង្កេតជាក់លាក់ ទៅតាមប្រធានបទនីមួយៗស្របតាមសេចក្តីសង្កេតជាទូទៅដ៏វែងនេះ។

៣០. សូមបញ្ជាក់ថា សវនាការបណ្តឹងសាទុក្ខ គឺជាឱកាសចុងក្រោយរបស់លោក ខៀវ សំផន ក្នុងការនិយាយឱ្យគេស្តាប់។ បណ្តឹងសាទុក្ខរបស់គាត់មានភាពធំធេងជាងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ហើយបញ្ហាប្រឈមក៏ខុសគ្នាខ្លាំងដែរ[30]។ ថ្វីត្បិតតែតុលាការកំពូល ដែលជាកន្លែងសម្រេចសេចក្តីចុងក្រោយ អាចច្រានចោលការផ្តន្ទាទោស និងសម្រេចឱ្យរួចផុតពីបទចោទ ក៏ដោយ ក៏តុលាការកំពូលមិនអាចប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោស បន្ទាប់ពីមានបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាបានឡើយ[31]។

---

សាទុក្ខរបស់ ខៀវ សំផន ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ **F52/1**។ សូមមើល ជាអាទិ៍ កថាខណ្ឌ ៧ កថាខណ្ឌ ១២ និងកថាខណ្ឌ ១៣។

[29] អង្គភាពបកប្រែភាសាបានជូនដំណឹងថា ការបកប្រែជាភាសាបារាំងនឹងត្រូវបញ្ចប់ ប្រហែលជាថ្ងៃទី២១ ខែមីនា ឆ្នាំ២០២១។

[30] សូមមើល ជាអាទិ៍ សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលារបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់សួរដេញដោលសាក្សី SCW-5 ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ **F26/2/2** កថាខណ្ឌ ៦-៧ ដែលតុលាការកំពូលរម្លឹកអំពីភាពខុសគ្នាជាមូលដ្ឋាន រវាងតួនាទីរបស់ជនជាប់ចោទ នៅក្នុងការជំនុំជម្រះក្តីព្រហ្មទណ្ឌ និងតួនាទីរបស់សហព្រះរាជអាជ្ញា ក៏ដូចជាសហមេធាវីនាំមុខ។

[31] វិធាន ១១០(៤) នៃវិធានផ្ទៃក្នុង, សាលដីកាសំណុំរឿង ០០១ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ **F28** កថាខណ្ឌ ១៨, សាលដីកាសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **F36** កថាខណ្ឌ ៩៤។

៣១. សវនាការបណ្ដឹងសាទុក្ខ គឺជាឱកាសតែមួយគត់សម្រាប់មេធាវីការពារក្ដី ជាម្ចាស់បណ្ដឹងសាទុក្ខ ក្នុងការឆ្លើយតបទៅនឹងចម្លើយតបជាលាយលក្ខណ៍អក្សរដ៏វែងអន្លាយ របស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ ជាចុងបណ្ដឹងសាទុក្ខ។ លើសពីនេះទៀត មេធាវីការពារក្ដីត្រូវឆ្លើយតបតែទៅនឹងភាគីចោទប្រកាន់តែមួយគត់ បន្ថែមលើការឆ្លើយទៅនឹងសំណួររបស់តុលាការកំពូល ពីព្រោះមេធាវីការពារក្ដីមានមធ្យោបាយតិចតួចបំផុត ដើម្បីបំពេញភារកិច្ចនេះ[32]។

## ២. <u>សេចក្ដីសង្ខេបជាក់លាក់តាមប្រធានបទ</u>

### ២.១. <u>បណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី</u>

#### ២.១.១. <u>ពុំមានប្រធានបទជាក់លាក់អំពីមូលដ្ឋានបណ្ដឹងសាទុក្ខចម្បងរបស់មេធាវីការពារក្ដី</u>

៣២. នៅក្នុងបណ្ដឹងសាទុក្ខ ជាចម្បង មេធាវីការពារក្ដីស្នើសុំឱ្យធ្វើមោឃភាពសាលក្រម បន្ទាប់មក ជាជម្រើសម្យ៉ាងទៀត លើកលែងលោក ខៀវ សំផន ឱ្យរួចផុតពីបទចោទ និងចុងក្រោយ ជាជម្រើសមួយបែបទៀត បន្ធូរបន្ថយទោស[33]។ ក៏ប៉ុន្តែ ក្នុងកាលវិភាគបណ្ដោះអាសន្ន សម្រាប់សវនាការបណ្ដឹងសាទុក្ខ[34] ពុំមានប្រធានបទណាមួយត្រូវបានគ្រោងឡើងជាក់លាក់ ពាក់ព័ន្ធនឹងមូលដ្ឋានបណ្ដឹងសាទុក្ខ ដែលបានលើកឡើងជាចម្បងឡើយ។

៣៣. ដោយមើលឃើញពីសារៈសំខាន់នៃមូលដ្ឋានបណ្ដឹងសាទុក្ខនេះ ចំពោះមេធាវីការពារក្ដី ដែលខុសពីភាគីផ្សេងទៀត តុលាការកំពូលគប្បីចាប់ផ្ដើមសវនាការបណ្ដឹងសាទុក្ខពីប្រធានបទជាក់លាក់នេះ។ ដោយហេតុថាការបង្ហាញមូលដ្ឋានបណ្ដឹងសាទុក្ខនេះមានរយៈពេលខ្លីដែរ[35] ហើយសហព្រះរាជ

---

[32] ទោះបីជាមានសំណើដដែលៗពីសំណាក់មេធាវីការពារក្ដី សុំឱ្យផ្ដល់មធ្យោបាយបន្ថែម តាំងពីពេលដាក់សារណាតបរបស់សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ ចាប់ពីខែតុលា ឆ្នាំ២០២០ ក៏ដោយ ក៏មេធាវីការពារក្ដីទើបតែទទួលបាននាពេលថ្មីៗនេះប៉ុណ្ណោះ។ ដូច្នេះ មេធាវីបានផ្លាស់ប្ដូរពីការធ្វើការមិនពេញម៉ោង ទៅពេញម៉ោង នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២១ និងអាចជ្រើសរើសអ្នកពិគ្រោះយោបល់ថ្មីពីរនាក់ នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១។

[33] សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់លោក ខៀវ សំផន (សំណុំរឿង ០០២/០២) ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ **E465/4/1** កថាខណ្ឌ ៣៥, សារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដីលោក ខៀវ សំផន (សំណុំរឿង ០០២/០២) ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ឯកសារ **F54** កថាខណ្ឌ ២១៨៥។

[34] ឧបសម្ព័ន្ធ - កាលវិភាគសវនាការ ឯកសារ **F60.1**។

[35] សារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដីលោក ខៀវ សំផន (សំណុំរឿង ០០២/០២) ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ឯក

អាជ្ញាបានឆ្លើយតបយ៉ាងសង្ខេបរួចហើយ[36] ឯសហមេធាវីនាំមុខមិនបានឆ្លើយតប ពេលវេលា ២០ នាទី សម្រាប់មេធាវីការពារក្តី និង ១០ នាទី សម្រាប់សហព្រះរាជអាជ្ញា គឺគ្រប់គ្រាន់ហើយ។

## ២.១.២. ប្រធានបទ "ភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី"

៣៤. ក្នុងកាលវិភាគបណ្តោះអាសន្ន ចំពោះវត្ថុស្តីពី "ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខពាក់ព័ន្ធទៅនឹងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី" មេធាវីការពារក្តីមានពេលវេលា ៤៥ នាទី ចំណែកឯសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ ទទួលបាន ៣៥ នាទី និង ២៥ នាទី រៀងគ្នា សរុប ៦០ នាទី ដើម្បីឆ្លើយតបទៅនឹងមេធាវីការពារក្តី[37]។

៣៥. ក្នុងសារណារបស់ខ្លួន មេធាវីការពារក្តីបានបរិយាយមូលដ្ឋានបណ្តឹងសាទុក្ខជាច្រើន ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃការជំនុំជម្រះក្តី រួមបញ្ចូល ជាអាទិ៍ បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចបន្ទាន់បង្ខំ និងមូលដ្ឋានបណ្តឹងសាទុក្ខពាក់ព័ន្ធនឹងវិធីសាស្ត្រទូទៅស្តីពីភ័ស្តុតាងរបស់អង្គជំនុំជម្រះសាលាដំបូង។ ក្នុងសំណុំរឿង ០០២/០១ មេធាវីការពារក្តីទទួលបានពេលវេលា ៣៥ នាទី ដើម្បីបង្ហាញមូលដ្ឋានបណ្តឹងសាទុក្ខស្តីពីភាពត្រឹមត្រូវនៃការជំនុំជម្រះក្តី និង ២០ នាទី ដើម្បីបង្ហាញមូលដ្ឋានបណ្តឹងសាទុក្ខពាក់ព័ន្ធនឹងវិធីសាស្ត្រទូទៅស្តីពីភ័ស្តុតាង ស្មើនឹង ៥៥ នាទី[38]។ ដើម្បីឆ្លើយតបទៅនឹងម្ចាស់បណ្តឹងសាទុក្ខពីរនាក់ សហព្រះរាជអាជ្ញាមានពេលវេលាសរុប ៥៥ នាទី លើបញ្ហាទាំងពីរនេះ ហើយសហមេធាវីនាំមុខទទួលបាន ១៥ នាទី លើវិធីសាស្ត្រទូទៅស្តីពីភ័ស្តុតាង[39]។

---

សារ F54 កថាខណ្ឌ ៣០-៧៩។

[36] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ជំទាស់ទៅនឹងសាលក្រមនៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ ឯកសារ F54/1 កថាខណ្ឌ ២៤-២៨។

[37] ឧបសម្ព័ន្ធ - កាលវិភាគសវនាការ ឯកសារ F60.1 ទំព័រ ១។

[38] ឧបសម្ព័ន្ធ ក - កាលវិភាគស្តាពរសម្រាប់សវនាការ [សំណុំរឿង ០០២/០១] ឯកសារ F30/17.1 ទំព័រ ១-២។

[39] ឧបសម្ព័ន្ធ ក - កាលវិភាគស្តាពរសម្រាប់សវនាការ [សំណុំរឿង ០០២/០១] ឯកសារ F30/17.1 ទំព័រ ១-២។

៣៦. ដោយហេតុថាមូលដ្ឋានបណ្តឹងសាទុក្ខរបស់ខ្លួនលើបញ្ហាទាំងនេះ ក្នុងសំណុំរឿង ០០២/០២ មានទំហំធំជាង ក្នុងសំណុំរឿង ០០២/០១ មេធាវីការពារក្តីសមតែទទួលបានពេលវេលាដូចគ្នា គឺយ៉ាងហោចណាស់ ៥៥ នាទី ដើម្បីធ្វើសារណាតបទៅនឹងចម្លើយតបរបស់ភាគីបដិបក្ខ។

៣៧. ម្យ៉ាងវិញទៀត ការបង្ហាញចម្លើយតបរបស់សហមេធាវីនាំមុខត្រូវកំហិតត្រឹមតែបញ្ហាពាក់ព័ន្ធនឹងភ័ស្តុតាងដែលខ្លួនបានផ្តល់ជូន។ ថ្វីត្បិតតែបញ្ហានៅសេសសល់មានផលប្រយោជន៍ទូទៅសម្រាប់សហមេធាវីនាំមុខ ប៉ុន្តែ បញ្ហាទាំងនេះពាក់ព័ន្ធនឹងសហមេធាវីនាំមុខដោយប្រយោលប៉ុណ្ណោះ និងត្រូវបានសហព្រះរាជអាជ្ញាលើកឡើងរួចមកហើយ។ ដូច្នេះ ពេលវេលាធ្វើសារណារបស់សហមេធាវីនាំមុខគួរកម្រិតត្រឹម ១៥ នាទី បានហើយ។

## ២.១.៣. ប្រធានបទ “យុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង”

៣៨. ក្នុងកាលវិភាគបណ្តោះអាសន្ន ចំពោះវគ្គស្តីពី “ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខពាក់ព័ន្ធនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង” មេធាវីការពារក្តីទទួលបានពេលវេលា ៥៥ នាទី ចំណែកឯសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ ទទួលបាន ៥៥ នាទី និង ២០ នាទី រៀងគ្នា សរុប ៧៥ នាទី ដើម្បីឆ្លើយតបទៅនឹងមេធាវីការពារក្តី[40]។

៣៩. ទោះបីជាពាក់ព័ន្ធដោយប្រយោលនឹងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ក៏បញ្ហាទាំងនេះស្ថិតក្រោមសមត្ថកិច្ចរបស់សហព្រះរាជអាជ្ញា ដែលបានឆ្លើយតបយ៉ាងវែងអន្លាយរួចមកហើយ។ ដូច្នេះ សហមេធាវីនាំមុខមិនគួរត្រូវបានអនុញ្ញាតឲ្យធ្វើអន្តរាគមន៍លើប្រធានបទនេះទេ នៅក្នុងសវនាការ។

៤០. លើសពីនេះទៀត ពុំមានហេតុផលអ្វីដែលត្រូវផ្តល់ពេលវេលាឲ្យសហព្រះរាជអាជ្ញា ស្មើគ្នានឹងមេធាវីការពារក្តីនោះឡើយ[41]។ ប្រសិនបើនេះជាឱកាសតែមួយគត់ សម្រាប់មេធាវីការពារក្តី ក្នុងការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា បន្ថែមពីលើការឆ្លើយទៅនឹងសំណួររបស់

[40] ឧបសម្ព័ន្ធ - កាលវិភាគសវនាការ ឯកសារ F60.1 ទំព័រ ១-២។

[41] សូមមើលខាងលើ កថាខណ្ឌ ៧។

ចៅក្រម មេធាវីការពារក្តីត្រូវទទួលបានពេលវេលាលើសសហព្រះរាជអាជ្ញា។ ដូច្នេះ មេធាវីការពារក្តីគួរទទួលបាន ៥៥ នាទី ហើយសហព្រះរាជអាជ្ញា ៤០ នាទី សម្រាប់ឆ្លើយតប ទើបជាការត្រឹមត្រូវ។

## ២.១.៤. ប្រធានបទ "បទឧក្រិដ្ឋដែល ខៀវ សំផន ត្រូវបានសម្រេចដាក់ពិរុទ្ធភាព"

៤១. ក្នុងកាលវិភាគបណ្តោះអាសន្ន ចំពោះវគ្គស្តីពី "ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខពាក់ព័ន្ធនឹងបទឧក្រិដ្ឋដែល ខៀវ សំផន ត្រូវបានសម្រេចដាក់ពិរុទ្ធ" មេធាវីការពារក្តីទទួលបានពេលវេលា ៤៥ នាទី ចំណែកឯសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ ទទួលបាន ៤០ នាទី រៀងៗខ្លួន សរុប ៨០ នាទី ដើម្បីឆ្លើយតបទៅនឹងមេធាវីការពារក្តី[42]។

៤២. ដោយហេតុថា លោក ខៀវ សំផន ត្រូវបានផ្តន្ទាទោស ក្នុងសំណុំរឿង ០០២/០២ ពីបទឧក្រិដ្ឋច្រើនជាង ក្នុងសំណុំរឿង ០០២/០១ មេធាវីការពារក្តីនឹងលើកឡើងនូវមូលដ្ឋានបណ្តឹងសាទុក្ខច្រើនជាងលើបញ្ហានេះ ដែលខ្លួនមិនបានធ្វើ ក្នុងសំណុំរឿង ០០២/០១។ ពេលនោះ មេធាវីការពារក្តីទទួលបាន ៣៥ នាទី ក្នុងសវនាការ ចំណែកសហព្រះរាជអាជ្ញាបានឆ្លើយតបទៅនឹងម្ចាស់បណ្តឹងសាទុក្ខពីរនាក់ ក្នុងរយៈពេល ៤០ នាទី[43]។

៤៣. ដោយសារតែបណ្តឹងសាទុក្ខរបស់ខ្លួន ក្នុងសំណុំរឿង ០០២/០២ មានទំហំធំជាង ក្នុងសំណុំរឿង ០០២/០១ ហើយនេះជាឱកាសតែមួយគត់របស់ខ្លួន ក្នុងការឆ្លើយតបទៅនឹងចម្លើយតបរបស់ចុងបណ្តឹងសាទុក្ខ បន្ថែមពីលើការឆ្លើយទៅនឹងសំណួររបស់តុលាការកំពូល មេធាវីការពារក្តីគួរទទួលបានពេលវេលា យ៉ាងហោចណាស់ ៦០ នាទី ដើម្បីធ្វើសារណា។

៤៤. ការប៉ាន់ប្រមាណនេះគិតដល់ការកម្រិតចម្លើយតបរបស់សហមេធាវីនាំមុខត្រឹមតែបញ្ហាពាក់ព័ន្ធនឹងភ័ស្តុតាងដែលខ្លួនបានផ្តល់ជូន។ ថ្វីត្បិតតែបញ្ហាច្បាប់ជាធរមានសុទ្ធសាធមានផលប្រយោជន៍ទូទៅសម្រាប់សហមេធាវីនាំមុខ ប៉ុន្តែ បញ្ហាទាំងនេះពាក់ព័ន្ធនឹងសហមេធាវីនាំមុខដោយប្រយោល

---

[42] ឧបសម្ព័ន្ធ - កាលវិភាគសវនាការ ឯកសារ **F60.1** ទំព័រ ២-៣។

[43] ឧបសម្ព័ន្ធ ក - កាលវិភាគស្អាតសម្រាប់សវនាការ [សំណុំរឿង ០០២/០១] ឯកសារ **F30/17.1** ទំព័រ ៣-៤។

ប៉ុណ្ណោះ និងត្រូវបានសហព្រះរាជអាជ្ញាលើកឡើងរួចមកហើយ។ ដូច្នេះ ពេលវេលាធ្វើសារណា របស់សហមេធាវីនាំមុខគួរកម្រិតត្រឹម ២០ នាទី បានហើយ។

## ២.១.៥. ប្រធានបទ "ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ ខៀវ សំផន"

៤៥. ក្នុងកាលវិភាគបណ្ដោះអាសន្ន ចំពោះវគ្គស្ដីពី "ទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខពាក់ព័ន្ធនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលរបស់ ខៀវ សំផន" មេធាវីការពារក្ដីទទួលបានពេលវេលា ៦០ នាទី ឯសហព្រះរាជអាជ្ញាក៏ទទួលបាន ៦០ នាទី ដែរ ដើម្បីឆ្លើយតបទៅនឹងមេធាវីការពារក្ដី[44]។

៤៦. ត្រង់នេះទៀត មេធាវីការពារក្ដីនឹងលើកឡើងអំពីមូលដ្ឋានបណ្ដឹងសាទុក្ខច្រើនជាង ក្នុងសំណុំរឿង ០០២/០១។ ក្នុងសំណុំរឿង ០០២/០១ មេធាវីការពារក្ដីទទួលបាន ៥០ នាទី ក្នុងសវនាការ ចំណែកឯសហព្រះរាជអាជ្ញាទទួលបាន ៥៥ នាទី ដើម្បីឆ្លើយតបទៅនឹងម្ចាស់បណ្ដឹងសាទុក្ខពីរនាក់[45]។

៤៧. ដោយសារវិសាលភាពនៃបណ្ដឹងសាទុក្ខរបស់ខ្លួនលើបញ្ហាទាំងនេះ ក៏ដូចជាសារៈសំខាន់ជាក់ស្ដែង និងដោយសារតែខ្លួនត្រូវការពេលវេលាច្រើនជាង ដើម្បីឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា បន្ថែមពីលើការឆ្លើយទៅនឹងសំណួររបស់តុលាការកំពូល មេធាវីការពារក្ដីគួរទទួលបានពេលវេលា យ៉ាងហោចណាស់ ៧៥ នាទី ដើម្បីធ្វើសារណា។

## ២.១.៦. ប្រធានបទ "ការប្រកាសទោស"

៤៨. ក្នុងកាលវិភាគបណ្ដោះអាសន្ន ចំពោះវគ្គស្ដីពី "ទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខពាក់ព័ន្ធទៅនឹងការប្រកាសទោស" មេធាវីការពារក្ដីទទួលបានពេលវេលា ៣០ នាទី ចំណែកសហព្រះរាជអាជ្ញា និង

---

[44] ឧបសម្ព័ន្ធ - កាលវិភាគសវនាការ ឯកសារ **F60.1** ទំព័រ ៣-៤។

[45] ឧបសម្ព័ន្ធ ក - កាលវិភាគស្ដាពរសម្រាប់សវនាការ [សំណុំរឿង ០០២/០១] ឯកសារ **F30/17.1** ទំព័រ ៥។

សហមេធាវីនាំមុខ ទទួលបាន ១៥ នាទី និង ១០ នាទី រៀងគ្នា សរុប ២៥ នាទី ដើម្បីឆ្លើយតបទៅនឹងមេធាវីការពារក្តី[46]។

៤៩. បញ្ហាទោសមិនប៉ះពាល់ដោយផ្ទាល់ដល់ផលប្រយោជន៍ដោយឡែក របស់ដើមបណ្តឹងរដ្ឋប្បវេណីទេ និងស្ថិតក្រោមសមត្ថកិច្ចផ្តាច់មុខរបស់សហព្រះរាជអាជ្ញា ដែលបានឆ្លើយតបរួចមកហើយទៅនឹងមូលដ្ឋានបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី។ ដូច្នេះ សហមេធាវីនាំមុខមិនគួរត្រូវបានអនុញ្ញាតឱ្យធ្វើអន្តរាគមន៍លើប្រធានបទនេះ ក្នុងសវនាការ ឡើយ ហើយម្យ៉ាងទៀត ដោយសារពួកគេមិនបានបង្ហាញទឡ្ហីករណ៍លើប្រធានបទនេះឡើយ នៅក្នុងសារណាតបរបស់ខ្លួន។

៥០. ម្យ៉ាងវិញទៀត ដោយសារ ជាចម្បង លោក ខៀវ សំផន ស្នើសុំឱ្យធ្វើមោឃភាពសាលក្រម និងជាបន្ទាប់បន្សំ ស្នើសុំលើកលែងឱ្យរួចផុតពីបទចោទ បញ្ហាបន្ទាប់បន្សំបំផុតនៃទោសមិនតម្រូវឱ្យប្រើពេលវេលាទាំងអស់ ដូចបានផ្តល់ជូន ក្នុងកាលវិភាគបណ្តោះអាសន្ន នោះឡើយ។ ដោយហេតុថា មេធាវីការពារក្តីនឹងមិនលើកឡើងអំពីមូលដ្ឋានបណ្តឹងសាទុក្ខច្រើន ដូចក្នុងសំណុំរឿង ០០២/០១ ដែលពេលនោះ មេធាវីការពារក្តីទទួលបាន ១៥ នាទី និងសហព្រះរាជអាជ្ញា ១០ នាទី ដើម្បីឆ្លើយតបទៅនឹងមេធាវីការពារក្តី[47]។

៥១. ក្នុងករណីនេះ ការផ្តល់ពេលវេលា ១៥ នាទី ឱ្យមេធាវីការពារក្តី និង ១០ នាទី សម្រាប់ចម្លើយតបរបស់សហព្រះរាជអាជ្ញា គឺអាចគ្រប់គ្រាន់ហើយ និងជាអាទិ៍ អាចឱ្យមេធាវីការពារក្តីទទួលបានពេលវេលាច្រើនជាងលើបញ្ហាផ្សេងទៀតដែលមានអាទិភាពជាង នៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួន ឧទាហរណ៍ មូលដ្ឋានបណ្តឹងសាទុក្ខចម្បងអំពីមោឃភាពនៃសាលក្រម។

---

[46] ឧបសម្ព័ន្ធ - កាលវិភាគសវនាការ ឯកសារ **F60.1** ទំព័រ ៦។

[47] ឧបសម្ព័ន្ធ ក - កាលវិភាគស្តាពរសម្រាប់សវនាការ [សំណុំរឿង ០០២/០១] ឯកសារ **F30/17.1** ទំព័រ ៤។

## ២.២. បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា

៥២. បើតាមកាលវិភាគបណ្ដោះអាសន្ន តុលាការកំពូលគ្រោងឲ្យសហព្រះរាជអាជ្ញាបង្ហាញបណ្ដឹងសាទុក្ខរបស់ខ្លួន រយៈពេល ៣០ នាទី ហើយមេធាវីការពារក្ដីឆ្លើយតប រយៈពេល ២០ នាទី បន្ទាប់មក សហមេធាវីនាំមុខឡើងធ្វើអន្តរាគមន៍ រយៈពេល ២០ នាទី[48]។

៥៣. ក៏ប៉ុន្តែ សហមេធាវីនាំមុខ ដែលជាអ្នក "គាំទ្រ" ដល់សហព្រះរាជអាជ្ញា[49] គួរតែឡើងធ្វើអន្តរាគមន៍បន្ទាប់ពីសហព្រះរាជអាជ្ញាវិញ ហេតុនេះអាចឲ្យមេធាវីការពារក្ដីឆ្លើយតបទៅនឹងសហមេធាវីនាំមុខផងដែរ និងគោរពតាមគោលការណ៍ចំពោះមុខ។

## ២.៣. វគ្គបិទសវនាការ

៥៤. បើតាមកាលវិភាគបណ្ដោះអាសន្ន វគ្គបិទសវនាការត្រូវបានគ្រោងធ្វើឡើង ដោយមានប្រធានបទពីរ៖ ១) "សំណួរចុងក្រោយរបស់អង្គជំនុំជម្រះ" រយៈពេល ៦០ នាទី និង ២) "ឱកាសសម្រាប់ជនជាប់ចោទថ្លែងទៅកាន់អង្គជំនុំជម្រះដោយផ្ទាល់" រយៈពេល ៣០ នាទី[50]។

៥៥. យោងតាមវិធាន ១០៩(៥) នៃវិធានផ្ទៃក្នុង[51] ក្នុងវគ្គស្ដីពីឱកាសសម្រាប់លោក ខៀវ សំផន ថ្លែងទៅកាន់ចៅក្រមដោយផ្ទាល់ មេធាវីការពារក្ដីចង់បានពេលវេលា ២០ នាទី ដែរ ដើម្បីបង្ហាញអំពីសេចក្ដីសង្កេតបន្ថែមខ្លីៗជាយថាហេតុ។

[48] ឧបសម្ព័ន្ធ - កាលវិភាគសវនាការ ឯកសារ **F60.1** ទំព័រ ៥។

[49] សូមមើលខាងលើ កថាខណ្ឌ ១៥។

[50] ឧបសម្ព័ន្ធ - កាលវិភាគសវនាការ ឯកសារ **F60.1** ទំព័រ ៥។

[51] ដកស្រង់ខាងលើ នៅកថាខណ្ឌ ៥៖ "គ្រប់ករណីទាំងអស់ ជនជាប់ចោទត្រូវនិយាយក្រោយគេបំផុត។ មេធាវីរបស់ជនជាប់ចោទត្រូវបានអនុញ្ញាតឲ្យធ្វើសេចក្ដីសន្និដ្ឋានតបដោយសង្ខេប"។

**សេចក្តីសន្និដ្ឋាន**

៥៦. ដើម្បីឲ្យកាន់តែមានភាពច្បាស់លាស់ថែមទៀត មេធាវីការពារក្តីសូមធ្វើការបូកសរុបសំណើរបស់ខ្លួន នៅក្នុងតារាងខាងក្រោម៖

| **បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី** | **មេធាវីការពារក្តី** | **សហព្រះរាជអាជ្ញា** | **សហមេធាវីនាំមុខ** |
|---|---|---|---|
| មោឃភាពនៃសាលក្រម | ២០ នាទី | ១០ នាទី | - |
| ភាពត្រឹមត្រូវ | ៥៥ នាទី | ៣៥ នាទី | ១៥ នាទី |
| បណ្តឹង/យុត្តាធិការ | ៥៥ នាទី | ៤០ នាទី | - |
| បទឧក្រិដ្ឋ | ៦០ នាទី | ៤០ នាទី | ២០ នាទី |
| ការទទួលខុសត្រូវ | ៧៥ នាទី | ៦០ នាទី | - |
| ទោស | ១៥ នាទី | ១០ នាទី | - |
| | | | |
| សរុប | ២៨០ នាទី (៤ ម៉ោង និង ៤០ នាទី) | ១៩៥ នាទី (៣ ម៉ោង និង ១៥ នាទី) | ៣៥ នាទី |
| | ២៨០ នាទី (៤ ម៉ោង និង ៤០ នាទី) | ២៣០ នាទី (៣ ម៉ោង និង ៥០ នាទី) | |

| | **សហព្រះរាជអាជ្ញា** | **សហមេធាវីនាំមុខ** | **មេធាវីការពារក្តី** |
|---|---|---|---|
| **បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា** | ៣០ នាទី | ២០ នាទី | ២០ នាទី |
| សរុប | ៥០ នាទី | | ២០ នាទី |

| | | |
|---|---|---|
| **វគ្គបិទសវនាការ** | ការថ្លែងរបស់ជនជាប់ចោទ និងមេធាវីជាចុងក្រោយ | ៥០ នាទី |

៥៧. សំណើសមហេតុផលបំផុតទាំងនេះមិនអូសបន្លាយពេលវេលាសរុប នៃសវនាការបណ្ដឹងសាទុក្ខ តាមការគ្រោងទុករបស់តុលាការកំពូល នោះឡើយ[52] ពីព្រោះវាមានសារៈសំខាន់ សម្រាប់ឱ្យលោក ខៀវ សំផន អាចឡើងថ្លែងជាចុងក្រោយ ដោយគោរពតាមគោលការណ៍ចំពោះមុខ និងសមភាពនៃមធ្យោបាយតទល់ក្ដី ដោយមិនប្រឈមមុខនឹងអង្គភាពចោទប្រកាន់ពីរ។

៥៨. ក្នុងស្មារតីនេះ ទោះបីជានេះជាគឺបំណងប្រាថ្នាឥតប្រយោជន៍ នៅចំពោះមុខនិន្នាការក៏ដោយ ក៏តុលាការកំពូលមិនត្រូវពិចារណាលើទឡ្ហីករណ៍របស់សហមេធាវីនាំមុខ ក្នុងសារណាតបរបស់ពួកគេឡើយ ពីព្រោះពួកគេបានធ្វើហួសពីបុព្វសិទ្ធិ និងលក្ខខណ្ឌរឹតត្បិតដែលបានដាក់[53]។

៥៩. **<u>អាស្រ័យហេតុនេះ</u>** មេធាវីការពារក្ដីស្នើសុំអង្គជំនុំជម្រះតុលាការកំពូលមេត្តា**ពិចារណា**លើសេចក្ដីសង្កេតនេះទាំងមូល និង**ឯកភាព**តាមការស្នើសុំទាំងអស់ ដែលត្រូវបានសង្ខេបជាសេចក្ដីសន្និដ្ឋាន ពីកថាខណ្ឌ ៥៦ ដល់កថាខណ្ឌ ៥៨។

| | | |
|---|---|---|
| មេធាវី **គង់ សំអុន** | ទីក្រុងភ្នំពេញ | |

[52] ពេលវេលាសរុបត្រូវបានកាត់បន្ថយ ៥ នាទី ថែមទៀតផង។

[53] បើតាមមេធាវីការពារក្ដី ដែលនៅដំណាក់កាលនេះ មិនអាចមានភាពច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ ដោយសារតែគ្មានការបកប្រែជាភាសាបារាំងដែលនឹងបញ្ចប់នាពេលខាងមុខ តុលាការកំពូលត្រូវពិចារណាតែទឡ្ហីករណ៍ពាក់ព័ន្ធផ្ទាល់មុខនឹងភ័ស្តុតាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវបានបង្ហាញនៅក្នុងផ្នែក "៨. ភ័ស្តុតាង និងការពិចារណាលើភ័ស្តុតាង" "៩. មូលដ្ឋាននានាពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម និងការយល់ឃើញផ្នែកអង្គហេតុ" (លើកលែងទឡ្ហីករណ៍អំពីច្បាប់ជាធរមាន) និង "១០. សារណាពាក់ព័ន្ធនឹងដើមបណ្ដឹងរដ្ឋប្បវេណីជាក់លាក់" នៃសារណាតប (ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ទៅនឹងបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២១ ឯកសារ **F54/2**)។

| | | |
|---|---|---|
| មេធាវី **Anta GUISSÉ** | ទីក្រុងប៉ារីស | |